**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងការិយាល័យអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ទៅជា នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង កិច្ចការអាស៊ាន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាលទៅជា " អគ្គនាយកដ្ឋានរដ្ឋបាល " នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

មាត្រា១ : ត្រូវបានតម្លើងការិយាល័យអាស៊ាន និង អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៃនាយកដ្ឋានទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

មាត្រា២ : នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំលើកគំរោងសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ និងអាស៊ាន ដែលពាក់ព័ន្ធនិងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ តាមគោលការណ៍របស់រាជរដ្ឋាភិបាល
- រៀបចំសំណុំលិខិតផ្សេងៗ ដែលពាក់ព័ន្ធនិងសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន សំរាប់ចរចា និងចុះហត្ថលេខាលើកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀង
- ប្រមូលផ្តុំមតិយោបល់លើសន្ធិសញ្ញាអន្តរជាតិដែលតម្រូវឱ្យក្រសួងចូលរួមមតិ
- តាមដានការអនុវត្តនីរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានចែងក្នុងកំណត់ហេតុអនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា
- តាមដាន និងស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងសហភាពប្រៃសណីយ៍សកល (UPU) សហភាពប្រៃសណីយ៍ ប៉ាស៊ីហ្វិច (APPU) សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ទូរគមនាគមន៍អាស៊ីប៉ាស៊ីហ្វិច (APT)
- ចូលរួមការងារដែលទាក់ទងនិងមហាអនុតំបន់ទន្លេមេគង្គ (GMS)
- សហការ និង សំរបសំរួលជាមួយនាយកដ្ឋានជំនាញក្នុងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ និង លេខាធិការដ្ឋានអាស៊ាន លើការងារសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន
- លើកគំរោងចំណាយប្រចាំឆ្នាំសំរាប់ដំណើរការកិច្ចសហប្រតិបត្តិការអន្តរជាតិ និង កិច្ចការអាស៊ាន
- រៀបចំកិច្ចប្រជុំ និងឯកសារ សំរាប់កិច្ចប្រជុំពាក់ព័ន្ធនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន
- បូកសរុបលទ្ធផលការងារសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន ។

មាត្រា៣ : នាយកដ្ឋាននេះដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា៤ : រចនាសម្ព័ន្ធនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង កិច្ចការអាស៊ាន ដែលមានការិយាល័យមួយចំនួន ចំណុះ និងការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងការិយាល័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

មាត្រា៥ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់គ្រងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៥*

ស្តាយករដ្ឋមន្ត្រី

ហ៊ុន សែន

**បានយកសេចក្តីជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

សូរ ឃុន

**<u>កន្លែងទទួល</u>**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ-កាលប្បវត្តិ*